លេខ ID <Consumer ID>

<Participant Given Name> < Participant Family Name >
<Preferred Mailing Address>
<Preferred Mailing Address >
<Locality> <State> <Postcode>

ជូនចំពោះ <Participant Given Name> < Participant Family Name >

## ការធ្វើតេស្តដោយឥតគិតថ្លៃរបស់លោកអ្នក

**ពលរដ្ឋអូស្ត្រាលីប្រហែលជា 80 នាក់ស្លាប់រៀងរាល់សប្តាហ៍ ដោយសារជំងឺមហារីកពោះវៀន។**

| | |
|---|---|
| **តើនេះជាអ្វី?** | នេះគឺជាការធ្វើតេស្តពិនិត្យរកមើលជំងឺមហារីកពោះវៀនដោយឥតគិតថ្លៃរបស់លោកអ្នក។ វាជាការសំខាន់ដែល លោកអ្នកធ្វើតេស្តនេះ ទោះបីជាលោកអ្នកមិនមានរោគសញ្ញាណាមួយក៏ដោយ។ ជំងឺមហារីកពោះវៀនអាចកើត ឡើងដោយគ្មានរោគសញ្ញា ហើយការធ្វើតេស្តនេះអាចរកឃើញការចេញនូវសញ្ញាព្រមានដំបូង មុនពេលមហារីក ពោះវៀនចាប់កើតមានឡើង។ ប្រសិនបើរកឃើញបានឆាប់ គេអាចព្យាបាលជំងឺមហារីកពោះវៀនបានដោយជោគ ជ័យ៩០ភាគរយ។ |
| **តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?** | ឧបករណ៍ធ្វើតេស្ត និងកូនសៀវភៅព័ត៌មានរបស់លោកអ្នកមានភ្ជាប់មកជាមួយនឹងលិខិតនេះ។ នេះគឺជាការធ្វើ តេស្តងាយស្រួល និងរហ័សដែលលោកអ្នកអាចធ្វើបាននៅផ្ទះរបស់លោកអ្នក។ សូមធ្វើតាមការណែនាំដោយ ប្រុងប្រយ័ត្ន ឬទូរស័ព្ទសុំជំនួយទៅខ្សែទូរស័ព្ទផ្តល់ជំនួយនៃកម្មវិធីនេះលេខ 1800 930 998។<br>ប្រសិនបើលោកអ្នកមានរោគសញ្ញាណាមួយ ដូចបានរៀបរាប់ក្នុងកូនសៀវភៅព័ត៌មាននេះ ឬមានប្រវត្តិគ្រួសារ មានជំងឺមហារីកពោះវៀន សូមពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក មុនពេលធ្វើតេស្តនេះ។ |
| **តើមានរឿងអ្វីកើតឡើងបន្ទាប់មក?** | លោកអ្នកនឹងទទួលបានលទ្ធផលក្នុងរង្វង់ពេលបីសប្តាហ៍។ លោកអ្នកត្រូវបានណែនាំឲ្យទាក់ទងវេជ្ជបណ្ឌិតអំពី លទ្ធផលរបស់លោកអ្នក។ **លទ្ធផលវិជ្ជមានមិនបញ្ជាក់ថាលោកអ្នកមានជំងឺមហារីកពោះវៀនឡើយ** ក៏ប៉ុន្តែវាអាច ជាសញ្ញាព្រមានដំបូង។ លទ្ធផលរបស់លោកអ្នក នឹងផ្តល់ជូនសម្រាប់តែលោកអ្នក កម្មវិធីនេះ និងវេជ្ជបណ្ឌិតរបស់ លោកអ្នកប៉ុណ្ណោះ។ |
| **តើលោកអ្នកមានសំណួរណាមួយឬទេ?** | សូមពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក ទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទផ្តល់ព័ត៌មានរបស់កម្មវិធីនេះ លេខ 1800 118 868 ឬបើកមើលវិបសាយរបស់យើងខ្ញុំ www.cancerscreening.gov.au។<br>ប្រសិនបើលោកអ្នកមិនចង់ធ្វើតេស្តនេះទេ សូមបំពេញទម្រង់បែបបទនៅផ្នែកខាងក្រោយនៃកូនសៀវភៅព័ត៌មាន ហើយចោលឧបករណ៍ធ្វើតេស្តដែលលោកអ្នកមិនបានប្រើទៅក្នុងធុងសំរាម។ សូមកុំឲ្យឧបករណ៍ធ្វើតេស្តរបស់ លោកអ្នក ទៅមនុស្សម្នាក់ផ្សេងទៀតឲ្យសោះ។ |

**ការធ្វើតេស្តនេះ អាចជួយសង្គ្រោះជីវិតរបស់លោកអ្នក។**

សាស្ត្រាចារ្យ Brendan Murphy
ប្រធានវេជ្ជសាស្ត្រ

<DATE>

NBCSR XXXX